# សេចក្តីថ្លែងការណ៍
# ស្តីពី
# ជំហានក្នុងការពង្រឹងឯករាជ្យភាពរបស់មន្ត្រីជាប់ឆ្នោត

សមាគម អង្គការសង្គមស៊ីវិល (រាយនាមខាងក្រោម) យល់ឃើញថា វត្តមានរបស់ក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក/ខណ្ឌ (ចំនួនសរុប ៣២៣៥[១] នាក់ ក្នុងនោះស្ត្រីចំនួន ១២.៣%) ពីគណបក្ស ប្រជាជនកម្ពុជា (២៥៥១ នាក់/អាសនៈ) គណបក្ស សម រង្ស៊ី (៥៧៩ អាសនៈ) គណបក្ស នរោត្តម រណប្ញទ្ធិ (៤៤ អាសនៈ) និង គណបក្ស ហ្វ៊ុនស៊ិនប៉ិច (៦១ អាសនៈ) គឺជាជំហានចាប់ផ្តើមក្នុងការជំរុញការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បើទោះបីប្រព័ន្ធបោះឆ្នោតបែបអសកលតាមបញ្ជីគណបក្សក្នុងការបង្កើតក្រុមប្រឹក្សានេះ ដែលមិនទាន់ស្របតាមលក្ខណៈប្រជាធិបតេយ្យក៏ដោយ។

ដំណើរការបោះឆ្នោតក្រុមប្រឹក្សានេះ បាននាំមកនូវផលវិបាកនៃការអនុវត្តសកម្មភាពមិនល្អមួយចំនួនទាក់ទិនការទិញ និងលក់សន្លឹកឆ្នោត ឬ/និងការដាក់សម្ពាធឱ្យស្បថដែលជាអំពើខុសច្បាប់ក្នុងពេលឃោសនាបោះឆ្នោត។

មានទទ្បីករណ៏ និងការចោទប្រកាន់គ្នាទៅវិញទៅមកដែលមន្ត្រីគណបក្សប្រជាជនកម្ពុជាត្រូវបានចោទថា បានទិញសន្លឹកឆ្នោតតាមរយៈការសន្យាផ្តល់ថវិកា និងផលប្រយោជន៏ផ្សេងទៀតទៅអង្គអ្នកបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្ស សម រង្ស៊ី។ ចំណែកគណបក្ស សម រង្ស៊ី ក៏ត្រូវបានចោទប្រកាន់ថា បានដាក់សម្ពាធឱ្យសមាជិករបស់ក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួនស្បថ ដោយប្រើប្រាស់ពាក្យធ្ងន់ៗដើម្បីធានាការស្បថ ដើម្បីគោរពគោលការណ៏បក្សក្នុងពេលបោះឆ្នោត។ អ្វីជាការព្រួយបារម្ភរបស់អង្គការ សង្គមស៊ីវិលគឺថា ទាំងមុនការបោះឆ្នោត និងក្រោយពេលបោះឆ្នោត "ក្រុមប្រឹក្សា" នេះ គណបក្ស សម រង្ស៊ី បានកំពុងជំរុញការដក ឬព្យួរសមាជិកមួយចំនួនចេញពីសមាជិកភាពក្រុមប្រឹក្សា ឃុំ-សង្កាត់។

---

[១] ការបូកសរុបពីលទ្ធផលបោះឆ្នោតក្រុមប្រឹក្សា ប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី ២៧ ឧសភា ឆ្នាំ ២០០៩

គណបក្សសមរង្ស៊ី ក្រោយពីការបោះឆ្នោតក្រុមប្រឹក្សាបានប្រកាសជាសាធារណៈបណ្តេញសមាជិកក្រុមប្រឹក្សាយ៉ាងតិចចំនួន៩នាក់ចេញពីបក្ស ហើយយ៉ាងហោចណាស់ មានចំនួនជាង៣០០នាក់ ទៀតកំពុងតែប្រឈមនឹងការដក ឬព្យួរ។ ការដក ឬព្យួសមាជិកភាពពីគណបក្ស ឬក្រុមប្រឹក្សា ឃុំ-សង្កាត់ ត្រូវបានធ្វើតាមរយៈការបង្ខំ ឬតាមគោលការណ៍ស្ម័គ្រចិត្តឱ្យលាឈប់ ក្រោមការចោទប្រកាន់ថា "ក្បត់" "លក់ខ្លួន" ឬ "មិនគោរពគោលការណ៍គណបក្ស" ឬ "មិនបានបោះឆ្នោតឱ្យគណបក្ស"។

កន្លងមកគណបក្សជាច្រើនក៏បានដកសមាជិកខ្លួនពីសមាជិកភាពមន្ត្រីជាប់ឆ្នោតចេញពីសភា ព្រឹទ្ធសភា រហូតក្រុមប្រឹក្សាឃុំ-សង្កាត់ដែរ។

លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងប្រធានសមាគមអាដហុក (ADHOC) បានមានប្រសាសន៍ថា "ការដកតំណែងពីសមាជិកសភា ព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ចេញដោយគ្រាន់តែបាត់សមាជិកភាពពីគណបក្សនោះ មិនមែនជាគោលការណ៍ប្រជាធិបតេយ្យទេ។ ឥទ្ធិពលនយោបាយនៅតែបន្តគ្របដណ្តប់យ៉ាងខ្លាំងបន្តទៅទៀតទៅលើស្ថាប័នរដ្ឋ និងរដ្ឋបាលសាធារណៈ ដោយមិនមានការបែងចែកឱ្យច្បាស់លាស់ពីគ្នា រវាងតួនាទីនៅក្នុងស្ថាប័នរដ្ឋ និងសមាជិកភាពគណបក្សនយោបាយនោះឡើយ។

ប៉ុន្តែអ្វីជាប្រភពគន្លឹះនៃបញ្ហានេះ គឺច្បាប់បោះឆ្នោតក៏ដូចជាច្បាប់គ្រប់គ្រងក្រុមប្រឹក្សាទាំងឡាយនោះដែលបានផ្តល់អំណាចឱ្យគណបក្សដកសមាជិកខ្លួន ពីសមាជិកភាពណាមួយនៃក្រុមប្រឹក្សាទាំងនេះនៅពេលពួកគេបានបាត់បង់សមាជិកភាពរបស់គណបក្សនោះ។

លោក សុក សំអឿន អ្នកសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជានាយកប្រតិបត្តិ អង្គការការពារសិទ្ធិកម្ពុជា (CDP) ផ្តល់យោបល់ថា ដើម្បីដោះស្រាយរឿងនេះ មាត្រាខាងលើក្នុងច្បាប់ទាំងនេះគួរត្រូវបានដកចេញ ដែលផ្តល់ឱ្យមន្ត្រីជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់ ពីព្រឹទ្ធសភា រដ្ឋសភា រហូតដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានលទ្ធភាពបំពេញតួនាទី និងសិទ្ធិអំណាចដោយឯករាជ្យនៅក្នុងមួយអាណត្តិពេញដោយមិនស្ថិតក្រោមការគំរាមកំហែងរបស់គណបក្សដើម្បីដកសមាជិកភាពជាមន្ត្រីជាប់ឆ្នោត។

**អង្គការ សង្គមស៊ីវិលស្នើអនុសាសន៍ដូចតទៅៈ**

១- ត្រូវលុបមាត្រានៅក្នុងច្បាប់បោះឆ្នោតទាំងឡាយ ឬ/និងក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សាទាំងនេះ ដែលថា "ការបាត់បង់សមាជិកភាពគណបក្សនាំមកនូវការបាត់បង់សមាជិកភាពពី ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក/ខណ្ឌ និងឃុំ-សង្កាត់នោះចេញ" ។

២- ផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា និងក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក/ខណ្ឌ ទៅជាប្រព័ន្ធបោះឆ្នោតសកល និងផ្ទាល់ដែលអាចដាក់ និងចាត់ចែងដំណើរការបោះឆ្នោតនេះជាមួយការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ ឬការបោះឆ្នោតជ្រើសតាំងសមាជិកសភា។

៣- ធ្វើវិសោធនកម្មទៅលើច្បាប់បោះឆ្នោតទាំងនេះ បន្ថែមទោសពិន័យ និងបញ្ជាក់ឱ្យច្បាស់អំពីសកម្មភាពទិញសន្លឹកឆ្នោត រួមទាំងការសន្យាឱ្យលុយ និងការបង្ខំអ្នកបោះឆ្នោតឱ្យស្បថបោះឆ្នោតឱ្យគណបក្សខ្លួន។ បញ្ជាក់បន្ថែមក្នុងច្បាប់អំពីតួនាទី/សិទ្ធិអំណាច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ក្នុងការត្រួតពិនិត្យ និងបើកចំហរបាយការណ៍ថវិកាគណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត។

*ភ្នំពេញ, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩*

***<u>សមាគម អង្គការសង្គមស៊ីវិល និងអ្នកទាក់ទងពត៌មានបន្ថែម :</u>***

**១-លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ទូរស័ព្ទលេខ: ០១៦ ៨៨ ០៥០៩**

**២-លោក សុក សំអឿន អ្នកសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្ម ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩**

**៣-លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល ទូរស័ព្ទលេខ ០១២ ៩៤២ ០១៧**

**៤-លោក ហង្ស ពុទ្ធា នាយកប្រតិបត្តិនិចហ្វិក ០១២ ៩៥ ៩៦ ៦៦**